**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨-៧១-២៨២ ស.ជ.ណ

ថ្ងៃអង្គារ ៨កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
# ស្តីពី
# ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ
# ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី៩០

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបថា ប្រតិបត្តិការ LPCO លើកទី៩០ ដែលមានឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ នឹងដាក់ឱ្យដេញថ្លៃនៅថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១។ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងទំហំទឹកប្រាក់ដេញថ្លៃមានដូចតទៅ៖

| ប្រភេទ LPCO | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | ទឹកប្រាក់ដេញថ្លៃអតិបរមា |
|---|---|---|
| ៩១ថ្ងៃ | ១០.០០០.០០០.០០០ (ដប់ប៊ីលាន) រៀល | មិនកំណត់ |
| ១៨២ថ្ងៃ | ២០.០០០.០០០.០០០ (ម្ភៃប៊ីលាន) រៀល | មិនកំណត់ |
| ៣៦៤ថ្ងៃ | ៥០.០០០.០០០.០០០ (ហាសិបប៊ីលាន) រៀល | មិនកំណត់ |

<u>កំណត់សំគាល់</u> : ចំនួនទឹកប្រាក់ដេញថ្លៃឈ្នះអតិបរមាមានកម្រិត ២០% នៃទឹកប្រាក់ដាក់ដេញថ្លៃនៃឥណប្រតិទាននីមួយៗ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាប និងត្រៀមលក្ខណៈចូលរួមការដេញថ្លៃតាមកាលបរិច្ឆេទខាងលើ តាមការគួរ។

សូមទំនាក់ទំនង៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨)
សារអេឡិចត្រូនិក : lpco_info@nbc.org.kh